ស្វាគមន៍តែមាត់ ?

របបនៅភ្នំពេញ ទុក សម រង្ស៊ី ជាទណ្ឌឌិត, តែនៅពេលនរៈនេះ ប្រកាសថា វិលត្រឡប់ចូលស្រុក ទោះបីនៅក្នុងគោលដៅបែបណាក៏ដោយ គួរតែសប្បាយចិត្ត ព្រោះអាចចាប់ទណ្ឌឌិត ដាក់ពន្ធនាគារ, តែបែរជាបញ្ជាឱ្យ អាកាសចរស៊ិវិលកម្ពុជា ប្រាមមិនឱ្យក្រុមហ៊ុនអាកាសចរទាំងឡាយ ដឹក ទណ្ឌឌិតនេះ និងបក្សពួក ចូលមកស្រុកខ្មែរ។ តាមធ្មតានៅប្រទេស មានទីតិរដ្ឋ បំរាមនេះ វាផ្ទុយនឹងដីកាចាប់ខ្លួន សម រង្ស៊ី ដែលអាចឱ្យតុលាការ ផ្តន្ទាទោស ដល់អាកាសចរស៊ីវិល ព្រោះ ជាការប្រឆាំងនឹងដំណើរការ នៃច្បាប់។ តែនៅស្រុកខ្មែរ ច្បាប់វានៅលើតែសំដីរង៉ាប់រង្គូរបស់ ហ៊ុន សែន ចង់បាន ជួនកាល វាជាសំដីប្រឆាំងនឹងខ្លួនឯងទៀតផង, ដូចយ៉ាង ស្វាគមន៍ ដល់មាតុភូមិនិវត្តរបស់ រង្ស៊ី ព្រោះ គុក រង់ចាំ, តែផ្ទុយទៅវិញ បែរជាប្រមូលកម្លាំងអាវុធ ដើររដឹក មានទាំងរថក្រោះ ដើម្បីខាយាំង មិនឱ្យ រង្ស៊ី ជាបុគ្គលម្នាក់ ចូលស្រុកបាន តាមព្រំដែនខ្មែរ-ថៃ។ ទង្វើនេះ មានរូបភាពអាប់ឱន គួរឱ្យអាម៉ាស់ និង គួរឱ្យអាសូរផងដល់ ហ៊ុន សែន ដែលគាត់យកឧបកិច្ច[1] ទាំងរអាមកធ្វើជាកិច្ចការរដ្ឋ ដែលអាចទុកជាប្រផ្នូលមិនល្អ មួយ សំរាប់អវាសាន នៃរបបផ្តាច់ការនៅភ្នំពេញ៕

---

[1] ឧបកិច្ច ៖ កិច្ចការផ្ទាល់ខ្លួន។

ឧប សៅ សន្ធា **គំនិត** **៣ វិច្ឆិកា ២០១៩**